# សេចក្តីសង្ខេបនៃការយល់ដឹងស៊ីជម្រៅទៅលើ អ្នកប្រើប្រាស់បរិយាបន្នឌីជីថល — អតីតជន ភៀសខ្លួន និងជនចំណាកស្រុកដែលប្រើ ភាសាអង់គ្លេសជាភាសាទីពីរ ។




Te Tari Taiwhenua
Internal Affairs

Te Kāwanatanga o Aotearoa
New Zealand Government

# 1. សេចក្ដីផ្ដើម

បរិយាបន្នឌីជីថលអាចឱ្យនិយមន័យថាជាស្ថានភាពចុងក្រោយដែលមនុស្សគ្រប់រូបមានឱកាស ប្រកបដោយសមធម៌ដើម្បីចូលរួមក្នុងសង្គមដោយប្រើបច្ចេកវិទ្យាឌីជីថលនានា (Digital Inclusion Research Group, 2017)។

របាយការណ៍ស្ដីពីបទពិសោធន៍របស់អ្នកប្រើប្រាស់ (UX)សម្រាប់អតីតជនភៀសខ្លួន និងជនចំណាកស្រុក ដែលពុំសូវបានទទួលការយកចិត្តទុកដាក់ គឺជាផ្នែកដែលមាននៅក្នុងរបាយការណ៍ស្ដីពីការយល់ដឹង ស៊ីជម្រៅទៅលើអ្នកប្រើប្រាស់បរិយាបន្នឌីជីថលជាស៊េរី ដែលអនុញ្ញាតឲ្យធ្វើឡើងដោយ Te Tari Taiwhenua ក្រសួងមហាផ្ទៃ (DIA)។ គោលបំណងនៃរបាយការណ៍ជាស៊េរីនេះ គឺដើម្បីស្វែងយល់ពី បទពិសោធន៍ការរស់នៅរបស់ក្រុមមនុស្សដែលជារឿយៗត្រូវបានផាត់ចេញពីការប្រើប្រាស់បច្ចេកវិទ្យា ឌីជីថល ។

អតីតជនភៀសខ្លួន និងជនចំណាកស្រុកដែលពុំសូវទទួលបានការយកចិត្តទុកដាក់ក៏ជាក្រុមគោលដៅ មួយដែលបានទទួលការជ្រោមជ្រែងតិចតួចពីគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល បើប្រៀបនឹងក្រុមដទៃ ដូចអ្វីដែលបានរាយការណ៍នៅក្នុងរបាយការណ៍របស់រដ្ឋាភិបាលស្តីពីប្រជាសាស្ត្រគោលដៅ ។

សូមអានផ្នែក 2 នៃរបាយការណ៍ ៖ <u>ការវាយតម្លៃឡើងវិញនូវបរិយាបន្នឌីជីថល ៖ តើបរិយាបន្នឌីជីថល មានស្ថានភាពបែបណានៅក្នុងជួររដ្ឋាភិបាល</u> ។

ការស្រាវជ្រាវរៀបចំឡើងដើម្បី៖

- កំណត់ឧបសគ្គ ការប្រឈម និងបញ្ហាកើតឡើងមិនឈប់នៃដំណើរនៃបរិយាបន្នឌីជីថលរបស់ អតីតជនភៀសខ្លួន និងជនចំណាកស្រុកដែលពុំសូវទទួលបានការយកចិត្តទុកដាក់
- ស្វែងយល់ថាតើក្រុមនេះចូលរួមប្រើប្រាស់បច្ចេកវិទ្យាឌីជីថលបានប៉ុណ្ណា នៅក្នុងក្របខ័ណ្ឌបរិយា បន្នឌីជីថល ។

ការស្រាវជ្រាវនេះសិក្សាទៅលើបទពិសោធន៍នៃការតាំងទីលំនៅរបស់ក្រុមនេះនៅ Aotearoa ប្រទេស នូវែលសេឡង់នៅក្នុងអំឡុងពេលទាំងអស់នេះ — គឺអំឡុងពេល3 ខែដំបូង និង3 ឆ្នាំដំបូង ។

ការស្រាវជ្រាវនេះបានធ្វើឡើងពីខែមេសា ដល់ខែមិថុនា ឆ្នាំ2021 នៅ 6 តំបន់នានាទូទាំងប្រទេសនូវែល សេឡង់។ ជាសរុប មានអ្នកចូលរួមចំនួន 41 នាក់ តំណាងឱ្យក្រុមជនជាតិនានាចំនួន 20 ។ សម្ភាសន៍ ស៊ីជម្រៅជាមួយអ្នកចូលរួមត្រូវបានធ្វើឡើងមួយទល់មួយ និងទល់មុខគ្នា ។ នៅពេលចាំបាច់ យើងមាន ជំនួយពីអ្នកបកប្រែភាសាផ្ទាល់មាត់ដោយផ្ទាល់ ឬតាមទូរស័ព្ទ។

## សេចក្តីថ្លែងអំណរគុណ

ក្រសួងមហាផ្ទៃ (DIA) សូមថ្លែងអំណរគុណយ៉ាងកក់ក្តៅបំផុតដល់ជនគ្រប់រូបដែលបានចែករំលែករឿងរបស់ពួកគេ និងបានចូលរួមនៅក្នុងគម្រោងស្រាវជ្រាវពីបទពិសោធន៍របស់អ្នកប្រើប្រាស់ (UX)។ ក្រុមបរិយាបន្នឌីជីថលក៏សូមថ្លែងអំណរគុណដល់ក្រសួងទទួលបន្ទុកសហគមន៍ជនជាតិភាគតិចដែលបានធ្វើការជាមួយអ្នកស្រាវជ្រាវដើម្បីសម្របសម្រួលដល់ការចូលរួមរបស់សហគមន៍ ដោយរួមមានអង្គការក្រៅរដ្ឋាភិបាល (NGOs) ដើម្បីរៀបចំសម្ភាសន៍ និងផ្តល់ការណែនាំ និងព័ត៌មានត្រឡប់ ។

ក្រសួងមហាផ្ទៃ (DIA) សូមបញ្ជាក់ថាព័ត៌មាន និងការរកឃើញដែលមាននៅក្នុងរបាយការណ៍នេះគឺឆ្លុះបញ្ចាំងពីទស្សនៈរបស់បុគ្គលដែលបានចូលរួមក្នុងសម្ភាសន៍ និងក្រុមផ្សេងៗដែលពួកគេតំណាងឱ្យ ។

## ព័ត៌មានក្នុងរបាយការណ៍

រៀបចំសម្រាប់ Te Tari Taiwhenua ក្រសួងមហាផ្ទៃ និងក្រសួងទទួលបន្ទុកសហគមន៍ជនជាតិភាគតិច ។

រៀបចំដោយ Jas Hua។

កាលបរិច្ឆេទ ៖ ថ្ងៃទី30 ខែវិច្ឆិកា ឆ្នាំ2021

### សេចក្តីដកស្រង់

Hua, J។ (ឆ្នាំ2021ខែវិច្ឆិកា)។ ‘សេចក្តីសង្ខេបនៃការយល់ដឹងស៊ីជម្រៅទៅលើអ្នកប្រើប្រាស់បរិយាបន្នឌីជីថល — អតីតជនភៀសខ្លួន និងជនចំណាកស្រុកដែលប្រើភាសាអង់គ្លេសជាភាសាទីពីរ។’ បកប្រែចេញពីរបាយការណ៍ជាភាសាអង់គ្លេស ក្រសួងមហាផ្ទៃ ។ https://www.digital.govt.nz/dmsdocument/195~summary-of-digital-inclusion-user-insights-former-refugees-and-migrants-with-english-as-a-second-language/html



# 2. ការរកឃើញសំខាន់ៗ

ផ្នែកនេះសង្ខេបការរកឃើញសំខាន់ៗដែលស្រង់ពីការវិភាគទៅលើអត្ថបទសំណេរ និងការស្រាវជ្រាវដែលបានធ្វើ ហើយកត្តាផ្សេងៗទៀតដែលប៉ះពាល់ដល់បរិយាបន្នឌីជីថលរបស់អតីតជនភៀសខ្លួន និងជនចំណាកស្រុកដែលពុំសូវទទួលបានការយកចិត្តទុកដាក់។

លទ្ធភាពប្រើប្រាស់ និងបំណិនគឺជាឧបសគ្គចម្បង2 ដល់បរិយាបន្នឌីជីថលសម្រាប់អតីតជនភៀសខ្លួន និងជនចំណាកស្រុកដែលពុំសូវទទួលបានការយកចិត្តទុកដាក់ ។

កត្តាផ្សេងៗទៀតដែលបង្កើតឧបសគ្គដល់បរិយាបន្នឌីជីថលសម្រាប់ក្រុមនេះគឺ ៖

- ជំនាញភាសាអង់គ្លេសមានកម្រិតទាបជាងអ្នកដទៃ
- ឧបសគ្គផ្នែកវប្បធម៌
- ស្ថានភាពសេដ្ឋកិច្ចសង្គមមានកម្រិតទាប ។

## 2.1. សេចក្ដីសង្ខេបនៃការវិភាគទៅលើអត្ថបទសំណេរ

យើងបានស្វែងរកអត្ថបទសំណេរដែលមានស្រាប់ស្ដីពីបរិយាបន្នឌីជីថលសម្រាប់អតីតជនភៀសខ្លួន និងជនចំណាកស្រុកដែលប្រើភាសាអង់គ្លេសជាភាសាទីពីរ(ESL) នៅប្រទេសនូវែលសេឡង់ និងប្រទេសផ្សេងៗទៀតជុំវិញពិភពលោកពីមូលដ្ឋានទិន្នន័យចំនួនប្រាំ ។ ការចម្រាញ់ព័ត៌មានដំបូងនៅក្នុងសេចក្ដីសង្ខេបបានធ្វើកំណត់ត្រាចំនួន 36 ។ ចេញពីសេចក្ដីសង្ខេបនេះ យើងបានពិនិត្យឡើងវិញនូវកំណត់ត្រានីមួយៗ ដើម្បីកំណត់រកមើលភាពពាក់ព័ន្ធទៅនឹងវិសាលភាពនៃការស្រាវជ្រាវ ។

ការយល់ដឹងស៊ីជម្រៅក៏ត្រូវបានប្រើដើម្បីផ្ដល់ព័ត៌មានដល់ផែនការស្រាវជ្រាវផងដែរ ។

### ភាពខុសគ្នានៃនិយមន័យ និងបទពិសោធន៍ រវាង 'ជនភៀសខ្លួន' និង 'ជនចំណាកស្រុក'

មានភាពខុសគ្នាផ្នែកច្បាប់យ៉ាងច្បាស់រវាងជនភៀសខ្លួន និងជនចំណាកស្រុកដែលត្រូវបានទទួលស្គាល់ដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅក្នុងសេចក្ដីប្រកាសនាក្រុងញូវយ៉កស្ដីអំពីជនភៀសខ្លួន និងជនចំណាកស្រុក (មហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ 2016) និងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR)។

ជនភៀសខ្លួន និងជនចំណាកស្រុកឆ្លងកាត់បទពិសោធន៍ផ្សេងៗគ្នា នៅពេលពួកគេមកដល់ប្រទេសថ្មី ។ នៅក្នុងប្រទេសនូវែលសេឡង់ ក្រុមជនទាំងនេះទទួលបានការគាំទ្រក្នុងការតាំងទីលំនៅផ្សេងៗគ្នា ដែលផ្ដល់ដោយក្រសួងអន្តោប្រវេសន៍ (INZ) ក្នុងភាពជាដៃគូជាមួយភ្នាក់ងាររដ្ឋាភិបាលផ្សេងៗទៀត និងអ្នកផ្ដល់សេវាជាភាគីទីបី ។

### ភាពស្រដៀងគ្នាដែលយើងបានដឹងរវាង 'ជនភៀសខ្លួន' និង 'ជនចំណាកស្រុកដែលពុំសូវទទួលបានការយកចិត្តទុកដាក់'

មានក្រុមជនចំណាកស្រុកដែលជួបការប្រឈមស្រដៀងគ្នាទៅនឹងការប្រឈមដែលក្រុមអតីតជនភៀសខ្លួនជួបប្រទះ ក្នុងដំណើរនៃការតាំងទីលំនៅរបស់ពួកគេ ។ ការប្រឈមទាំងនេះរួមមានការប្រឈមផ្នែកសង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយ ។ អង្គការជួយជនភៀសខ្លួន និងជនចំណាកស្រុក Belong Aotearoa និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀតនៅក្នុងប្រទេសនូវែលសេឡង់ពិពណ៌នាក្រុមនេះថាជា 'ជនចំណាកស្រុកដែលពុំសូវទទួលបានការយកចិត្តទុកដាក់' ។ (Belong Aotearoa, UMMA Trust,

RASNZ, NZ Red Cross, Asylum Seekers Support Trust, Aotearoa Resettled Community Coalition, Family Action, 2020)។

ជាសង្ខេប មានកម្រិតនៃភាពរួមខ្ពស់រវាងអតីតជនភៀសខ្លួន និងជនចំណាកស្រុកដែលពុំសូវទទួលបានការយកចិត្តទុកដាក់ដែលត្រូវការទទួលបានសេវាគាំទ្រនានាសម្រាប់ការតាំងទីលំនៅរបស់ពួកគេ ។ មានភាពរួមតិចជាងរវាងអតីតជនភៀសខ្លួន និងក្រុមជនចំណាកស្រុកដទៃទៀត ដូចជាជនចំណាកស្រុកដែលមានជំនាញជាដើម ។ ការផ្តោតចម្បងក្នុងការសិក្សាស្រាវជ្រាវនេះគឺទៅលើអតីតជនភៀសខ្លួន និងជនចំណាកស្រុកដែលពុំសូវទទួលបានការយកចិត្តទុកដាក់ ។

## ប្រធានបទសំខាន់ៗដែលបានរកឃើញចេញពីការវិភាគទៅលើអត្ថបទសំណេរ

- មានឧបសគ្គនានាចំពោះការប្រើប្រាស់ព័ត៌មានតាមអនឡាញពីប្រភពផ្លូវការដោយជនភៀសខ្លួន និងជនចំណាកស្រុកដែលទើបមកដល់ក្នុងពេលថ្មីៗនេះ ។
- បច្ចេកវិទ្យាឌីជីថលអាចជួយឱ្យជនភៀសខ្លួន និងជនចំណាកស្រុកបំពេញតម្រូវការមួយនៃតម្រូវការសំខាន់ៗរបស់ពួកគេ ៖ ការទំនាក់ទំនងដែលមានតម្លៃសមរម្យដោយប្រើបណ្តាញសង្គមរបស់ពួកគេ ។ ទោះជាយ៉ាងណាក៏ដោយ ឧបសគ្គនានានៅតែមានចំពោះការប្រើប្រាស់ឧបករណ៍ឌីជីថលសម្រាប់ផលប្រយោជន៍របស់ពួកគេ ។
- មនុស្សដែលមានបរិយាបន្នឌីជីថលសម្រេចបាននូវការបញ្ចូលខ្លួនក្នុងសង្គម និងសុខុមាលភាពបានប្រសើរជាង ។

ដោយបានរកឃើញនៅក្នុងការវិភាគទៅលើអត្ថបទសំណេរ ប្រធានបទសំខាន់ៗទាំង 3 នេះជួយឆ្លើយសំណួរមួយផ្នែកនៅក្នុង របៀបវារៈនៃការស្រាវជ្រាវទៅលើបរិយាបន្នឌីជីថល ក៏ដូចជាផ្តល់ព័ត៌មានដល់វិសាលភាពនៃការស្រាវជ្រាវនេះផងដែរ ។

ឧបសគ្គនានាចំពោះបរិយាបន្នឌីជីថលសម្រាប់អតីតជនភៀសខ្លួន និងជនចំណាកស្រុកត្រូវបានផ្សំឡើងដោយកត្តាផ្សេងទៀត រួមទាំងការប្រឈមផ្នែកសង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយដែលកើតឡើងនៅពេលតាំងទីលំនៅនៅក្នុងប្រទេសម្ចាស់ផ្ទះថ្មីរបស់ពួកគេ ។

មានសម្មតិកម្មថាការលើកកម្ពស់សមាសធាតុនៃបរិយាបន្នឌីជីថល — ហេតុជំរុញទឹកចិត្ត លទ្ធភាពប្រើ បំណិន និងសេចក្តីទុកចិត្ត (MAST) — នឹងធ្វើឱ្យប្រសើរឡើងនូវបរិយាបន្នឌីជីថលរបស់ក្រុមនេះ ហើយដូច្នេះក៏ធ្វើឱ្យប្រសើរឡើងនូវកត្តានានាដែលពាក់ព័ន្ធនឹងដំណើរនៃការតាំងទីលំនៅរបស់ពួកគេដែរ ។

# 2.2. សេចក្តីសង្ខេបនៃលទ្ធផលសិក្សាស្រាវជ្រាវ

លទ្ធផលនៃការស្រាវជ្រាវត្រូវបានវិភាគដោយប្រើក្របខ័ណ្ឌ MAST ដែលរួមមានសមាសធាតុដែលពឹងពាក់គ្នាទៅវិញទៅមកចំនួន 4ដូចខាងក្រោម ៖ ហេតុជំរុញទឹកចិត្ត លទ្ធភាពប្រើ បំណិន និងសេចក្តីទុកចិត្ត ។

## ហេតុជំរុញទឹកចិត្ត

អតីតជនភៀសខ្លួន និងជនចំណាកស្រុកដែលពុំសូវទទួលបានការយកចិត្តទុកដាក់មួយចំនួនគ្មានបទពិសោធន៍ពីមុនក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថល អ៊ីនធឺណិត ឬសេវាអនឡាញទេ នៅមុនពេលមកដល់ប្រទេសនូវែលសេឡង់ ។ នេះបង្កើតឱ្យមានគម្លាតនៅក្នុងចំណេះដឹងរបស់ពួកគេស្តីពីអ្វីដែលអាចធ្វើដើម្បីសម្រេចបាន ដោយប្រើបច្ចេកវិទ្យាឌីជីថល។

ឋានានុក្រមនៃតម្រូវការមានអាទិភាព ហើយលទ្ធភាពផ្លូវចិត្តក្នុងការរៀនគឺកម្រមាន ។ សម្រាប់អ្នកដែលយល់ពីអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ចនៃបច្ចេកវិទ្យាឌីជីថល អត្ថប្រយោជន៍ទាំងនេះមិនសម្រេចបានទេ ដោយសារតែការខ្វះលទ្ធភាពប្រើប្រាស់ឧបករណ៍ និងបំណិនពាក់ព័ន្ធ ។ ការភ្ជាប់ទំនាក់ទំនង

ជាមួយក្រុមគ្រួសារ និងមិត្តភក្តិនៅក្រៅប្រទេសគឺជាហេតុជំរុញទឹកចិត្តដ៏ធំបំផុត និងការប្រើប្រាស់ស្មាតហ្វូនញឹកញាប់បំផុតសម្រាប់ក្រុមនេះ ។

> “ខ្ញុំត្រូវចំណាយពេលយូរណាស់ក្នុងការរៀនប្រើស្មាតហ្វូន ទោះជាយ៉ាងណាក្តីដូចជា មិត្តភក្តិ ឬមិត្តរួមថ្នាក់ដែលខ្ញុំធ្លាប់រៀនជាមួយ ពួកគេមានស្មាតហ្វូន ហើយពួកគេបានចាប់ផ្តើមប្រើប្រាស់វាមុនខ្ញុំបាត់ទៅហើយ ។ ខ្ញុំគ្មានស្មាតហ្វូនប្រើប្រាស់ភ្លាមៗនោះទេ ។ ម៉្យាងទៀត ខ្ញុំមិនបានដឹងថាការមិនចេះប្រើស្មាតហ្វូនគឺជាការប្រឈមនោះទេ ព្រោះខ្ញុំមិនដឹងថាស្មាតហ្វូនអាចធ្វើអ្វីបានខ្លះទេ ។ ហើយក្រោយមកខ្ញុំក៏បានសុំានឹងរបៀបរស់នៅរបស់ខ្ញុំខ្លះៗ រហូតដល់ពេលទូរស័ព្ទរបស់ខ្ញុំបានបែក ។ ហើយបន្ទាប់មកខ្ញុំត្រូវទិញស្មាតហ្វូនថ្មីមួយគ្រឿង ។ ហើយនៅទីបញ្ចប់យើងបានទិញស្មាតហ្វូនមួយគ្រឿងជូនម្តាយខ្ញុំ និងសម្រាប់ខ្លួនខ្ញុំផ្ទាល់ ។ ខ្ញុំត្រូវចំណាយពេលអស់ 3 ឆ្នាំ។”
>
> — អ្នកចូលរួមក្នុងការស្រាវជ្រាវ

## លទ្ធភាពប្រើប្រាស់

តម្លៃគឺជាឧបសគ្គចម្បងសម្រាប់ក្រុមនេះដើម្បីមានលទ្ធភាពប្រើឧបករណ៍ធំៗ ដូចជាកុំព្យូទ័រលើតុ កុំព្យូទ័រយួរដៃ ទិន្នន័យ និងគម្រោងទូរស័ព្ទចល័ត ហើយនិងគម្រោងអ៊ីនធឺណិតប្រើសេរីនៅផ្ទះ ។ ការតភ្ជាប់ទៅវ៉ាយហ្វាយ (wifi) សាធារណៈដោយមិនគិតថ្លៃត្រូវបានរាយការណ៍ថាដាច់ៗ មានល្បឿនយឺត ឬកំណត់ពេលវេលា ឬក៏ហេតុផលទាំងអស់ដូចខាងលើ ។

សម្រាប់ការចូលប្រើសេវារបស់រដ្ឋាភិបាល ការទៅដោយផ្ទាល់នៅតែត្រូវបានគេមើលឃើញថាជាមធ្យោបាយមានប្រសិទ្ធភាពជាងគេក្នុងការធ្វើកិច្ចការសំខាន់ៗ និងដោះស្រាយបញ្ហា និងសំណួរនានា ។

ក្នុងរយៈពេល 3 ខែដំបូង ការណាត់ជួបដោយផ្ទាល់ ឬតាមទូរស័ព្ទដោយមានសេវាបកប្រែផ្ទាល់មាត់គឺជារបៀបនៃការប្រើសេវាដែលនិយមជាងគេ ។ ការគាំទ្រនៃបណ្តាញសង្គមដូចជាអ្នកស្ម័គ្រចិត្ត បុគ្គលិកជួយក្នុងការតាំងទីលំនៅ សមាជិកគ្រួសារ ឬសមាជិកសហគមន៍ គឺជាគន្លឹះសម្រាប់ក្រុមនេះដើម្បីប្រើអ៊ីនធឺណិត ឧបករណ៍ និងសេវាសំខាន់ៗ មិនថាតាមអនឡាញ ឬមិនតាមអនឡាញឡើយ ។

ការប្រើស្វ័យសេវាកម្មតាមអនឡាញមិនអាចដំណើរការទៅរួចនោះទេ ដោយសារមានឧបសគ្គភាសាអង់គ្លេស កង្វះធនធានជាភាសាជនជាតិភាគតិច បំណិនឌីជីថលមានកម្រិត និងភាពមិនច្បាស់អំពីរបៀបដែលប្រព័ន្ធអនឡាញដំណើរការ ។ និន្នាការនេះភាគច្រើននៅតែមិនផ្លាស់ប្តូរសម្រាប់រយៈពេល 3 ឆ្នាំដំបូងនៃការតាំងទីលំនៅនៅក្នុងប្រទេសនូវែលសេឡង់សម្រាប់មនុស្សភាគច្រើននៃក្រុមនេះ ។

សម្រាប់អ្នកដែលមានបំណងប្រើស្វ័យសេវាកម្មតាមអនឡាញ វាស៊ីពេល ពីព្រោះពួកគេត្រូវការប្រើឧបករណ៍បកប្រែតាមអនឡាញដើម្បីជួយពួកគេឱ្យយល់ពីខ្លឹមសារ និងអែបនានា ។ ទោះបីជាពួកគាត់បានខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ពួកគេក៏នៅតែត្រូវការជំនួយក្នុងការឆ្លើយសំណួរ បំពេញតាមតម្រូវការ និងយល់ពាក្យបច្ចេកទេស ។

> “យើងមិនបានដឹងអ្វីទាំងអស់អំពីប្រទេសនូវែលសេឡង់ នៅមុនពេលយើងមកដល់ប្រទេសនេះ ។ ជាទូទៅ មុនពេលយើងបានមកដល់ប្រទេសនូវែលសេឡង់ យើងទទួលបានព័ត៌មានបន្តិចបន្តួចអំពីប្រទេសនូវែលសេឡង់ ។ និយាយតាមត្រង់ទៅ យើងមិនដឹងថាប្រទេសនូវែលសេឡង់ស្ថិតនៅឯណាទេ ។ នៅពេលខ្ញុំបានមកដល់ទីនេះ នៅទីភ្នាក់ងារជួយក្នុងការតាំងទីលំនៅឡើងវិញ ពួកគេផ្ដល់បុគ្គលិកគាំទ្រស្ម័គ្រចិត្ត [ម្នាក់] ដល់ខ្ញុំ គាត់បានជួយធ្វើអ្វីៗគ្រប់យ៉ាងឱ្យខ្ញុំ ដូចជារបៀបទៅទិញទំនិញ របៀបប្រើបណ្ណធនាគារ របៀបទៅការិយាល័យការងារ និងប្រាក់ចំណូល ឬរបៀបទៅសាលារៀន របៀបជិះឡានក្រុង ឬអ្វីៗគ្រប់យ៉ាងគឺជាអ្វីដែលបុគ្គលិកគាំទ្រនេះជួយខ្ញុំ ហើយណែនាំខ្ញុំ និងដឹកនាំខ្ញុំ និងគាំទ្រខ្ញុំ ក្នុងការតាំងទីលំនៅក្នុងសហគមន៍ថ្មី។”
>
> — អ្នកចូលរួមក្នុងការស្រាវជ្រាវ

## បំណិន

មានភ័ស្តុតាងដែលបញ្ជាក់ថាការបណ្តុះបណ្តាលបំណិនឌីជីថលដែលបានផ្តល់ជាភាសាជនជាតិភាគតិចអាចជួយសម្រួលដល់ដំណើរការនៃការទទួលបានបំណិនឌីជីថល ដោយមិនបាច់មានជំនាញភាសាអង់គ្លេស ។ ទោះជាយ៉ាងណាក៏ដោយ វាចាំបាច់ត្រូវមានការបែងចែកច្បាស់លាស់នូវកម្រិតបំណិនឌីជីថល ដើម្បីឱ្យការបណ្តុះបណ្តាលអាចមានប្រសិទ្ធភាព ។ សហគមន៍ដែលមានទំនុកចិត្តត្រូវបានចាត់ទុកថាជាអាជ្ញាកណ្តាលល្អបំផុតដើម្បីផ្ទេរចំណេះដឹង ផ្តល់ការគាំទ្រ និងសម្របសម្រួលការបណ្តុះបណ្តាលបំណិនឌីជីថល ។

ផ្នែកសំខាន់ជាងគេបង្អស់ចំនួន 3 នៃបំណិនឌីជីថលសម្រាប់ក្រុមនេះគឺ ៖

1. បំណិនប្រតិបត្តិការហិរញ្ញវត្ថុតាមអនឡាញ
2. បំណិនសុវត្ថិភាព និងសន្តិសុខតាមអនឡាញ
3. បំណិនគ្រប់គ្រងព័ត៌មាន និងខ្លឹមសារតាមអនឡាញ ។

បំណិនឌីជីថលជាក់លាក់កំពូលទាំង 5 នៃបំណិនឌីជីថលនានាដែលក្រុមនេះចង់រៀនឱ្យបានប្រសើរនោះគឺ ៖

1. ការរក្សាទុកព័ត៌មាននៅក្នុងក្លោដ៍ (cloud) និងការចូលប្រើខ្លឹមសារនោះពីឧបករណ៍ផ្សេងៗ
2. ការធ្វើបច្ចុប្បន្នភាពឧបករណ៍ឱ្យបានទៀងទាត់ដើម្បីការពារមេរោគ និងហានិភ័យផ្សេងៗ
3. ការគ្រប់គ្រងប្រាក់ និងប្រតិបត្តិការហិរញ្ញវត្ថុតាមអនឡាញប្រកបដោយសុវត្ថិភាព
4. ការទទួលបាន និងប្រើប្រាស់សេវាសាធារណៈតាមអនឡាញ ឧទាហរណ៍ ការចុះបញ្ជីយានយន្តតាមវិបសាយថ៍ MyMSD
5. ការបង់ថ្លៃទំនិញ ឬសេវាតាមអនឡាញ ។

កង្វះជំនាញភាសាអង់គ្លេសគឺជាឧបសគ្គយ៉ាងសំខាន់ក្នុងការទទួលបានបំណិនឌីជីថល ដោយសារការបណ្តុះបណ្តាលភាគច្រើនបំផុតត្រូវបានផ្តល់ជាភាសាអង់គ្លេស ។

> “ថ្នាក់រៀនដោយមិនគិតថ្លៃមានសារៈសំខាន់ណាស់សម្រាប់មនុស្សពេញវ័យ ពីព្រោះខ្ញុំចង់មានន័យថា សម្រាប់មនុស្សពេញវ័យ ទោះបីជាយើងមានកុំព្យូទ័រក៏ដោយ ក៏មនុស្សភាគច្រើនមិនអាចបើក[វា] បានទេ មិនដឹងពីរបៀបប្រើប្រាស់វា ដូច្នេះវគ្គសិក្សាកុំព្យូទ័រប្រភេទនេះមានសារៈសំខាន់ណាស់សម្រាប់ពួកគេ ។ ប៉ុន្តែ បញ្ហាទីពីរគឺវគ្គសិក្សានេះបង្រៀនជាភាសាអង់គ្លេស ។ នៅមានបញ្ហាធំមួយទៀត ។ ដូច្នេះ បើសិនមានអ្នកណាម្នាក់អាចបង្រៀនជាភាសារបស់យើង យើងនឹងពិតជាពេញចិត្តយ៉ាងខ្លាំងនឹងការបង្រៀនបែបនេះ ។ ពីព្រោះ បច្ចុប្បន្ននេះ បច្ចេកវិទ្យាមានប្រើនៅគ្រប់ទីកន្លែង ។ ដូច្នេះ នៅត្រង់ចំណុចនោះ យ៉ាងហោចណាស់ ជនគ្រប់រូបត្រូវការយល់ដឹងពីវគ្គសិក្សាមូលដ្ឋាន ។ ហើយដូចដែលយើងបាននិយាយរួចមកហើយ រដ្ឋាភិបាល ឬអង្គការជាច្រើនផ្តល់វគ្គសិក្សាទាំងនេះដោយមិនគិតថ្លៃ ប៉ុន្តែវានៅតែមានការពិបាកសម្រាប់យើងដដែល ។ ដោយសារយើងមិនចេះ ពួកយើងភាគច្រើនបំផុតមិនចេះភាសាអង់គ្លេស ។ ពាក្យបច្ចេកទេសកុំព្យូទ័រពិបាកយល់ជាងគេ ។”
>
> — អ្នកចូលរួមក្នុងការស្រាវជ្រាវ

ជំនឿចិត្តលើខ្លួនឯងទាប និងអាទិភាពនៃការបំពេញតម្រូវការរស់នៅជាមូលដ្ឋានប៉ះពាល់ដល់ការចូលរៀនជាប់លាប់ក្នុងថ្នាក់បណ្តុះបណ្តាលនានា ។

ស្ត្រីនៅក្នុងក្រុមនេះមានហានិភ័យខ្ពស់ជាងនៃការផាត់ចេញពីប្រព័ន្ធឌីជីថល ដោយសារមានកម្រិតបំណិនឌីជីថលទាប និងកង្វះឱកាស និងការគាំទ្រក្នុងការចូលរៀនវគ្គបណ្តុះបណ្តាល ភាគច្រើនដោយសារតែការបំពេញកិច្ចការថែទាំនៅតាមផ្ទះ ទទួលរងរបួស និងធ្លាក់ខ្លួនឈឺ ។

## សេចក្តីទុកចិត្ត

ការភ័យខ្លាចចំពោះព័ត៌មានផ្ទាល់ខ្លួន — រួមទាំងព័ត៌មានលម្អិតអំពីបណ្ណឥណទាន និងគណនីធនាគារ — ដោយខ្លាចថាមានគេតាមដាន មានគេដាក់អន្ទាក់ និងមានគេប្រមូលព័ត៌មានផ្ទាល់ខ្លួនសម្រាប់គោលបំណងដែលមិនពាក់ព័ន្ធ គឺជាប្រភពដ៏ធំបំផុតនៃការមិនទុកចិត្ត ។ ស្ថានភាពនេះបង្កើតឲ្យមានឧបសគ្គក្នុងការធ្វើសកម្មភាពតាមអនឡាញ ដូចជាការទិញទំនិញតាមអនឡាញ ប្រតិបត្តិការធនាគារតាមអនឡាញ និងការបង់ថ្លៃសម្រាប់សេវាសំខាន់ៗតាមអនឡាញ ។

> “រឿងដែលគួរឱ្យព្រួយបារម្ភជាងគេបំផុត និងមិនគួរទុកចិត្តជាងគេបំផុតដែលខ្ញុំមិនចូលចិត្ត គឺការលួចអត្តសញ្ញាណ ហើយអ្នកដឹង សម្រាប់ព័ត៌មានរបស់អ្នក សូមប្រុងប្រយ័ត្ន ព្រោះអ្នកមិនដឹងបានឡើយថាតើមនុស្សទាំងនេះនឹងលួចអត្តសញ្ញាណរបស់អ្នកឬក៏ឥត ហើយអ្នកមិនដឹងច្បាស់ថាអ្នកបានធ្វើអ្វីៗត្រឹមត្រូវដែរឬក៏ឥត នៅពេលបំពេញទម្រង់បែបបទនោះ។"
>
> — អ្នកចូលរួមក្នុងការស្រាវជ្រាវ

បទពិសោធន៍ផ្ទាល់ ឬបទពិសោធន៍តពីគេកាលពីមុននៃឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ដូចជាការលួចបន្លំ ការឆបោក និងការលបចូលលួចតាមអនឡាញក៏កាត់បន្ថយជំនឿទុកចិត្តនៅក្នុងពិភពឌីជីថលផងដែរ ។

បណ្តាញទំនាក់ទំនងសង្គមគឺជាបណ្តាញដែលមានទំនុកចិត្តច្រើនបំផុត បន្ទាប់មកគឺវិបសាយថ៍របស់រដ្ឋាភិបាល បណ្តាញព័ត៌មាន និងធនាគារ ទូរគមនាគមន៍ និងស្ថានីយផ្សាយព័ត៌មានដែលមានឈ្មោះល្បីៗ ។ ឥទ្ធិពលសង្គមក៏ជាកត្តាសំខាន់មួយដែលជួយសម្រួលដល់ការទទួលយកបច្ចេកវិទ្យាឌីជីថលផងដែរ ។

## 2.3. កត្តាផ្សេងទៀតដែលប៉ះពាល់ដល់បរិយាបន្នឌីជីថលរបស់ក្រុមនេះ

ក្រៅពីសមាសធាតុទាំង 4 នៅក្នុងក្របខ័ណ្ឌបរិយាបន្នឌីជីថល ក៏នៅមានកត្តាផ្សេងទៀតដែលប៉ះពាល់ដល់បរិយាបន្នឌីជីថលនៃក្រុមនេះដែរ ។

### កង្វះជំនាញភាសាអង់គ្លេស និងការយល់ដឹងអំពីសេវាដែលមានផ្តល់ជូន

កង្វះជំនាញភាសាអង់គ្លេស និងកង្វះធនធានជាភាសាជនជាតិភាគតិចគឺជាឧបសគ្គរយៈពេលវែងដល់បរិយាបន្នឌីជីថលនៃក្រុមនេះ ។

បញ្ហានេះកាន់តែធ្ងន់ធ្ងរឡើងដោយការខ្វះការយល់ដឹង ឬការយល់អំពីរបៀបដែលសេវានានាដំណើរការនៅប្រទេសនូវែលសេឡង់ ហើយព័ត៌មាន និងសេវារបស់រដ្ឋាភិបាលណាខ្លះដែលមានផ្តល់ជូន ជាពិសេសសម្រាប់អ្នកដែលគ្មានសិទ្ធិទទួលបានជំនួយតាមរយៈកម្មវិធីតាំងលំទីនៅថ្មីរបស់រដ្ឋាភិបាល ។

> "ខ្ញុំចង់មានន័យថា បើធៀបនឹងបច្ចេកវិទ្យាដែលមានក្នុងបច្ចុប្បន្ននេះ អ្វីៗទាំងអស់កាលពីមុនមានការលំបាកណាស់។ ប៉ុន្តែនៅពេលនោះ ដោយសារតែខ្ញុំមិនដឹងច្បាស់ថាតើអ្វីខ្លះជាសេវាសំខាន់ៗ ពីព្រោះអ្នកមិនបានដឹងច្បាស់អំពីអ្វីដែលអ្នកគ្មាននៅពេលនោះ ដូច្នេះអ្នកគ្រាន់តែធ្វើអ្វីទៅតាមលទ្ធភាព ហើយថែមទាំងមិនគិតថា 'អូ រឿងនេះពិបាក' អ្នកក៏ចេះតែធ្វើទៅ។"
>
> — អ្នកចូលរួមក្នុងការស្រាវជ្រាវ

### ឧបសគ្គផ្នែកវប្បធម៌

ចរិកលក្ខណៈនៃវប្បធម៌ត្រូវការយកមកពិចារណា នៅពេលលើកកម្ពស់ការយល់ដឹង ឬការផ្តល់សេវារដ្ឋាភិបាលនានា ឬក៏ទាំងលើកកម្ពស់ការយល់ដឹងផង និងផ្តល់សេវារដ្ឋាភិបាលផង - ជាពិសេសប្រសិនបើសេវានោះត្រូវផ្តល់ជូនតាមអនឡាញ ។ វប្បធម៌ខ្លះចាត់ទុកថាការសួរសំណួរ ឬសុំជំនួយជារឿងអាម៉ាស់ ។ មនុស្សខ្លះមិនចង់ឲ្យជួបប្រទះបញ្ហាបែបនេះទេ ដោយសារនាំឱ្យមានរឿងដល់អ្នកដទៃ ។ ការគិតបែបនេះនាំឱ្យមានការខ្វះខាតព័ត៌មានត្រឡប់ដល់អ្នកផ្តល់សេវា ជាពិសេសនៅពេលដែលសេវានានាមិនត្រូវបានផ្តល់ជូនឲ្យបានល្អតាមអនឡាញ ឬមិនតាមអនឡាញ - ឧទាហរណ៍ តាមទូរស័ព្ទ ឬនៅតាមមជ្ឈមណ្ឌលផ្តល់សេវា ។

> "ដូចជាការសួរសំណួរដើម្បីសុំជំនួយ ឬអ្វីៗដែលស្រដៀងគ្នានេះ ... ពីព្រោះវប្បធម៌នេះចាត់ទុកថាជារឿងខ្មាស់អៀនក្នុងការសួរថា ៖ តើអ្នកអាចជួយខ្ញុំបានឬទេ? [ដោយគិតត្រឡប់ក្រោយវិញ] ខ្ញុំនឹងធ្វើវាខុសពីមុន ខ្ញុំនឹងសួរ ទោះបីជាខ្ញុំមិនយល់ក៏ដោយ។"
>
> — អ្នកចូលរួមក្នុងការស្រាវជ្រាវ

### ស្ថានភាពសេដ្ឋកិច្ចសង្គម

ស្ថានភាពសេដ្ឋកិច្ចសង្គមមានកម្រិតទាបបង្កើតជាឧបសគ្គមួយផ្សេងទៀតចំពោះបរិយាបន្នឌីជីថលនៃក្រុមនេះ ជាពិសេសក្នុងការចូលប្រើឧបករណ៍ឌីជីថល ទិន្នន័យ និងគម្រោងទូរស័ព្ទចល័ត និងគម្រោងអ៊ីនធឺណិតប្រើសេរីនៅតាមផ្ទះ ។ ស្ថានភាពនេះប៉ះពាល់ដល់សមាសធាតុនៃហេតុជំរុញទឹកចិត្ត លទ្ធភាពប្រើប្រាស់ និងបំណិននៅក្នុងក្របខ័ណ្ឌ MAST ព្រោះវាត្រូវការពេលវេលាដើម្បីកែលម្អលក្ខខណ្ឌសេដ្ឋកិច្ចសង្គម ។

### ការទទួលបានការអប់រំ

ការទទួលបានការអប់រំថ្នាក់ឧត្តមសិក្សាហាក់ដូចជាមានទំនាក់ទំនងជាមួយនឹងកម្រិតខ្ពស់នៃបរិយាបន្នឌីជីថល ជាពិសេសនៅក្នុងសមាសធាតុជំនាញ ។ គេបានសង្កេតឃើញករណីនេះនៅក្នុងអតីតជនភៀសខ្លួនដែលបានបន្តការសិក្សា ឬកំពុងបន្តការសិក្សាថ្នាក់ឧត្តមសិក្សានៅប្រទេសនូវែលសេឡង់ និងនៅក្នុងជនចំណាកស្រុកមួយចំនួនដែលមានប្រវត្តិទទួលបានការអប់រំឧត្តមសិក្សា ។

## 2.4. បរិយាបន្នឌីជីថល និងសុខុមាលភាព

### លទ្ធភាពប្រើសេវាសង្គម

បរិយាបន្នឌីជីថលមានឥទ្ធិពលមួយផ្នែកដល់លទ្ធភាពប្រើប្រាស់សេវាកម្មសង្គមនានារបស់ក្រុមនេះក្នុងរយៈពេលវែង ជាពិសេសដោយមានការប្តូរទៅប្រើស្វ័យសេវាតាមអនឡាញកាន់តែច្រើនឡើង ។ សម្រាប់ក្រុមនេះ យើងបានឆ្លុះបញ្ចាំងពីភាពខុសគ្នារវាងលទ្ធភាពប្រើ និងរបៀបប្រើសេវាសង្គមនានា កាលនៅប្រទេសដើមរបស់ពួកគេ និងនៅប្រទេសនូវែលសេឡង់ ។ បញ្ហានេះកាន់តែធ្ងន់ធ្ងរទៅដោយសារកង្វះបទពិសោធន៍ពីមុនក្នុងការចូលប្រើប្រាស់អ៊ីនធឺណិត និងឧបករណ៍ឌីជីថល និងជំនាញភាសាអង់គ្លេសទាបសម្រាប់អតីតជនភៀសខ្លួន និងជនចំណាកស្រុកភាគច្រើន។ ស្ថានភាពនេះធ្វើឱ្យលទ្ធភាពប្រើប្រាស់សេវាសង្គមតាមអនឡាញជួបការប្រឈម ។

នៅក្នុងរយៈពេល 3 ខែដំបូងរបស់ពួកគេនៅប្រទេសនូវែលសេឡង់ ការគាំទ្ររបស់អ្នកស្ម័គ្រចិត្ត បុគ្គលិកជួយតាំងទីលំនៅ ក្រុមគ្រួសារ មិត្តភក្តិ និងសមាជិកសហគមន៍នានាគឺជាគន្លឹះក្នុងការចូលប្រើប្រាស់សេវាសំខាន់ៗ ។ របៀបចូលប្រើប្រាស់សេវាដែលនិយមជាងគេគឺការណាត់ជួបដោយផ្ទាល់ និងតាមទូរស័ព្ទ ។ និន្នាការនេះនៅតែបន្តមិនផ្លាស់ប្តូរក្នុងរយៈពេល 3 ឆ្នាំដំបូងរបស់ពួកគេនៅក្នុងប្រទេសថ្មីនេះ ។

### ទំនាក់ទំនងក្នុងសង្គម និងសុខុមាលភាពជាអត្តនោម័តិ

តម្លៃសមរម្យនៃស្មាតហ្វូនដែលមានការតភ្ជាប់អ៊ីនធឺណិតថិតថេរនៅក្នុងប្រទេសនូវែលសេឡង់ ដូចជាវ៉ាយហ្វាយ (wifi) នៅតាមផ្ទះបង្កើតវិធីសន្សំសំចៃ និងចីរភាពសម្រាប់ក្រុមនេះដើម្បីទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេ ។ ដូច្នេះ បរិយាបន្នឌីជីថលអាចជួយឱ្យក្រុមនេះអាចរក្សាទំនាក់ទំនងជាមួយគ្រួសារ និងសង្គមនៅឯបរទេស ដែលនឹងមិនអាចធ្វើបានឡើយ បើគ្មានបរិយាបន្នឌីជីថលទេនោះ ។ ការធ្វើបែបនេះផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់សុខុមាលភាពរបស់ពួកគេ ដោយកាត់បន្ថយអារម្មណ៍ឯកោ និងការកាត់ផ្តាច់ពីអ្នកដទៃ ជាពិសេសសម្រាប់អ្នកមកដល់ថ្មី ។

នៅពេលដែលការភ្ជាប់អ៊ីនធឺណិតត្រូវបានរំខាន វាប៉ះពាល់ជាអវិជ្ជមានទៅលើសុខុមាលភាពជាអត្តនោម័តិរបស់ពួកគេ ប្រសិនបើក្រុមនេះបាត់បង់ទំនាក់ទំនងជាមួយក្រុមគ្រួសារនៅឯបរទេសរបស់ពួកគេ

ដើម្បីចែករំលែកអំពីស្ថានភាពរបស់ពួកគេ ។ ការរអាក់រអួលនៅប្រទេសនូវលែសេឡង់អាចបណ្តាល មកពីការប្រើទិន្នន័យដល់កម្រិតកំណត់ ឬការដាច់អ៊ីនធឺណិត ។ នៅក្នុងប្រទេសដើមរបស់ពួកគេ ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ឬការតភ្ជាប់អាចនឹងត្រូវបានរំខានដោយព្រឹត្តិការណ៍នយោបាយសង្គម ឬតម្លៃអ៊ីនធឺណិតខ្ពស់ ។

> “ខ្ញុំក៏មានឪពុកម្តាយរបស់ខ្ញុំ បងប្អូនប្រុស និងស្រីរបស់ខ្ញុំចំនួន 2 នាក់នៅឯស្រុកកំណើតរបស់ខ្ញុំដែរ ។ ជាអកុសល ពួកគេមិនបានរស់នៅក្នុងស្ថានភាពល្អទេ ដោយសារមានសង្គ្រាមកំពុងតែបន្ត នៅក្នុងតំបន់នោះ ។ វាមានភាពតានតឹងក្នុងការគិតអំពីរឿងនេះ ។ វាជាការលំបាកខ្លាំងណាស់ ដោយសារបណ្តាញអ៊ិនថឺណិតនៅតែខ្សោយ ។ ដូច្នេះខ្ញុំហៅទូរស័ព្ទទៅពួកគេដោយផ្ទាល់តែម្តង ។ ខ្ញុំប្រើអែបផ្សេងដើម្បីហៅទូរស័ព្ទទៅពួកគេ ពីព្រោះសេវាធម្មតាមិនដំណើរការ ឬមិនអាចភ្ជាប់ខ្ញុំ បានទេ ។ បាទ ដូច្នេះខ្ញុំទើបតែបានតម្លើងអែប ។ យើងបញ្ចូលថ្មទូរស័ព្ទ និងហៅទូរស័ព្ទដោយ ផ្ទាល់ទៅកាន់ពួកគេ ប្រសិនបើវាដំណើរការ។ ហើយ វាមិនដំណើរទេក្នុងពេលថ្មីៗនេះ។”
>
> — អ្នកចូលរួមក្នុងការស្រាវជ្រាវ



# 3. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

មនុស្សភាគច្រើននៃក្រុមនេះគ្មានការរីកចម្រើនច្រើនផ្នែកបរិយាបន្នឌីជីថលរបស់ពួកគេទេ នៅពេលប្រៀបធៀបរយៈពេល 3 ខែដំបូង និងរយៈពេល3 ឆ្នាំដំបូងនៃអំឡុងពេលតាំងទីលំនៅក្នុងប្រទេសថ្មីនេះ ។ ទោះយ៉ាងណាក៏ដោយ គេមើលឃើញថាមានការរីកចម្រើននៃបរិយាបន្នឌីជីថលសម្រាប់អ្នកដែលមកតាំងទីលំនៅក្នុងប្រទេសនូវែលសេឡង់ក្នុងរយៈពេលវែងជាងនេះ—ឧទាហរណ៍ ច្រើនជាង10 ឆ្នាំ ។

នេះបង្កើតឱកាសមួយដើម្បីពន្លឿនដំណើរនៃបរិយាបន្នឌីជីថលរបស់ក្រុមនេះ ដោយដោះស្រាយសមាសធាតុលទ្ធភាពប្រើប្រាស់ និងជំនាញជាមុននៅក្នុងដំណើរនៃការតាំងទីលំនៅរបស់ពួកគេ ។

បណ្តាញសង្គមដូចជាអ្នកស្ម័គ្រចិត្ត បុគ្គលិកជួយក្នុងការតាំងទីលំនៅ សមាជិកសហគមន៍ និងសមាជិកគ្រួសារគឺជាប្រភពដែលមានទំនុកចិត្តច្រើនបំផុត បន្ទាប់មកមានបណ្តាញ និងវិបសាយថ៍ផ្លូវការនានារបស់រដ្ឋាភិបាល ។ ដូច្នេះ បណ្តាញទាំងនេះគួរតែត្រូវបានប្រើប្រាស់បន្ថែមទៀត ហើយបណ្តាញ និងវិបសាយថ៍ទាំងនេះគួរតែត្រូវបានរចនាឡើងជាពិសេសដើម្បីជួយកែលម្អបរិយាបន្នឌីជីថលរបស់ក្រុមនេះ ។

អនុសាសន៍ទាំងឡាយដូចខាងក្រោមគឺផ្អែកលើលទ្ធផលស្រាវជ្រាវ មិនមែនជាអនុសាសន៍គោលនយោបាយរបស់រដ្ឋាភិបាលឡើយ ។

## ឱកាសដើម្បីដោះស្រាយបញ្ហាលទ្ធភាពប្រើប្រាស់

ដើម្បីជួយដោះស្រាយបញ្ហាលទ្ធភាពប្រើប្រាស់ មានវិធានការមួយចំនួនដែលអាចជួយបានរួមមានការផ្តល់ជូននូវ ៖

- ឧបករណ៍ផ្សេងៗដូចជាកុំព្យូទ័រយួរដៃតាមរយៈជម្រើសហិរញ្ញវត្ថុផ្សេងៗគ្នា និងការភ្ជាប់អ៊ីនធឺណិតដែលត្រូវបានវាយតម្លៃថាជាវិធីសាស្រ្តមានប្រសិទ្ធភាពមួយ ។ កម្មវិធីលទ្ធភាពប្រើប្រាស់ប្រព័ន្ធឌីជីថលប្រកបដោយសមធម៌ (Equitable Digital Access) របស់ក្រសួងអប់រំ គឺជាឧទាហរណ៍មួយនៃវិធីសាស្រ្តជោគជ័យ
- ការប្រើប្រាស់ទិន្នន័យដែលមិនគិតថ្លៃដើម្បីចូលប្រើសេវាតាមអនឡាញសំខាន់ៗ រួមទាំងសេវាសំខាន់ៗរបស់រដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល
- ទីកន្លែងនៅក្នុងសហគមន៍ដូចជាបណ្ណាល័យសាធារណៈ និងទីកន្លែងគោរពបូជាដែលជាកន្លែងបណ្តុះបណ្តាលបំណិនឌីជីថល ហើយស្ថានីយ៍ឧបករណ៍ដែលពួកគេអាចចូលប្រើប្រាស់បាន ។

## ឱកាសដើម្បីដោះស្រាយបញ្ហាបំណិន

ដើម្បីជួយដោះស្រាយបញ្ហាបំណិន វិធានការនានាដែលអាចជួយបានរួមមានការផ្តល់នូវ ៖

- ការបណ្តុះបណ្តាលបំណិនឌីជីថលជាភាសាជនជាតិភាគតិចតាមរយៈអាជ្ញាកណ្តាលដែលមានទំនុកចិត្តដើម្បីកាត់បន្ថយពេលវេលាដែលក្រុមនេះនៅតែត្រូវបានគេផាត់ចេញពីការប្រើប្រាស់ប្រព័ន្ធឌីជីថល
- ការគាំទ្រតាមគោលដៅ និងទូលំទូលាយសម្រាប់ស្រ្តីនៅក្នុងសហគមន៍ជនជាតិភាគតិចជាពិសេសជុំវិញកិច្ចការថែទាំតាមផ្ទះ ដូច្នេះពួកគេអាចចូលរួមក្នុងថ្នាក់បណ្តុះបណ្តាលនានាបាន
- ការបណ្តុះបណ្តាលបំណិនឌីជីថលដោយមានកម្រិតសមិទ្ធិផលច្បាស់លាស់ ដូច្នេះវាមានប្រសិទ្ធភាព និងផ្តល់សិទ្ធិអំណាច ឧទាហរណ៍ ការបណ្តុះបណ្តាលបំណិនឌីជីថលជាក់លាក់សម្រាប់ប្រើស្មាតហ្វូនដែលជាចំណុចចាប់ផ្តើម នៅមុនពេលឈានទៅរៀនវគ្គបណ្តុះបណ្តាលបំណិនឌីជីថលពិបាកជាងនេះក្នុងការប្រើប្រាស់ឧបករណ៍ធំៗ ដូចជាកុំព្យូទ័រយួរដៃជាដើម

- ផ្តោតការបណ្តុះបណ្តាលទៅលើបំណិនឌីជីថលកំពូលទាំង3ដែលត្រូវបានកំណត់ថាមានសារៈសំខាន់សម្រាប់ក្រុមនេះ ៖ បំណិនប្រតិបត្តិការធនាគារតាមអនឡាញ ជំនាញសុវត្ថិភាព និងសន្តិសុខតាមអនឡាញ និងបំណិនក្នុងការគ្រប់គ្រងព័ត៌មាន និងខ្លឹមសារតាមអនឡាញ ។ នេះគួរតែរួមបញ្ចូលការបណ្តុះបណ្តាលលើការចូលប្រើសេវាតាមអនឡាញសំខាន់ៗដូចជា MyMSD myIR គណនីអន្តោប្រវេសន៍តាមអនឡាញ និងប្រតិបត្តិការធនាគារតាមអនឡាញ ។

## ការពិចារណាផ្សេងៗទៀត

ដើម្បីជួយបង្កើនបរិយាបន្នឌីជីថលរបស់អតីតជនភៀសខ្លួន និងជនចំណាកស្រុកដែលពុំសូវបានទទួលការយកចិត្តទុកដាក់ដែលកំពុងតាំងទីលំនៅក្នុងប្រទេសនូវែលសេឡង់ សូមពិចារណាលើ ៖

- ការបន្តផ្តល់អាទិភាពដល់ការបណ្តុះបណ្តាលជំនាញភាសាអង់គ្លេស
- ការធ្វើឱ្យមានធនធានជាភាសាជនជាតិភាគតិចតាមអនឡាញ ជាពិសេសសម្រាប់សេវាសំខាន់ៗ
- ការធ្វើឱ្យការបណ្តុះបណ្តាលបរិយាបន្នឌីជីថលជាផ្នែកនៃកម្មវិធីតាំងទីលំនៅថ្មីសម្រាប់អតីតជនភៀសខ្លួន និងជនចំណាកស្រុកដែលពុំសូវទទួលបានការយកចិត្តទុកដាក់ដោយមានកម្មវិធីបង្រៀន ភាសាអង់គ្លេសជាភាសាទីពីរ (ESL)
- ការវិនិយោគកាន់តែច្រើនក្នុងការបង្កើនការគាំទ្របរិយាបន្នឌីជីថលសម្រាប់រយៈពេល3 ទៅ 5 ឆ្នាំដំបូងនៃការតាំងទីលំនៅ
- ការប្រើការសិក្សាដោយសង្កេតភាពទាក់ទងគ្នាផ្សេងៗនៃប្រធានបទមួយក្នុងរយៈពេលវែងមួយដើម្បីយល់ពីផលប៉ះពាល់នៃការគាំទ្របរិយាបន្នឌីជីថលដំបូងទៅលើលទ្ធផលនៃការតាំងទីលំនៅ
- ការវាស់វែង និងតាមដានទីតាំងនៃបរិយាបន្នឌីជីថលរបស់ក្រុមនេះនៅក្នុងបរិបទនៃការតាំងទីលំនៅ និងលទ្ធផលនៃការតាំងទីលំនៅរបស់ពួកគេនៅក្នុងប្រទេសនូវែលសេឡង់ ។

> “ខ្ញុំមកពីបរទេស អ្នកបង្រៀនខ្ញុំភាសាអង់គ្លេស ហើយខ្ញុំរៀនភាសារបស់គាត់ ហើយខ្ញុំធ្វើការនៅទីនេះ ខ្ញុំបង់ពន្ធ ខ្ញុំជួយរដ្ឋាភិបាល ។ ដូច្នេះ ខ្ញុំនឹងមិនក្លាយជាជនឥតប្រយោជន៍ទេ ខ្ញុំនឹងក្លាយជាជនមានប្រយោជន៍ ។
>
> នៅពេលអ្នកបង្រៀនខ្ញុំគណិតវិទ្យា បូកនឹងភាសាអង់គ្លេស ខ្ញុំនឹងក្លាយជាជនមានប្រយោជន៍ច្រើនជាងនេះ ។ ខ្ញុំអាចធ្វើអ្វីបានអស្ចារ្យជាងពេលណាៗទាំងអស់ ។
>
> នៅពេលអ្នកបង្រៀនខ្ញុំកុំព្យូទ័រ ដូច្នេះខ្ញុំមានមូលដ្ឋានគ្រឹះនៃបច្ចេកវិទ្យាព័ត៌មាន ភាសាអង់គ្លេស និងគណិតវិទ្យា ។ ខ្ញុំនឹងក្លាយជាអ្នកជំនាញនៅពេលអនាគត ហើយខ្ញុំនឹងជួយប្រទេសនូវែលសេឡង់ឱ្យរីកចម្រើនកាន់តែលឿនជាងមុនថែមទៀត ។”
>
> — អ្នកចូលរួមក្នុងការស្រាវជ្រាវ



# 4. ឯកសារយោង


Belong Aotearoa, UMMA Trust, RASNZ, NZ Red Cross, Asylum Seekers Support Trust, Aotearoa Resettled Community Coalition, and Family Action. (ឆ្នាំ 2020). ‘Understanding social work provision to former refugees and marginalised migrant communities in Auckland.’ (PDF, 1.650 MB). https://static1.squarespace.com/static/5cca54599e483d0001fff53b/t/5f10c712d863ea7a41fc368a/1594935071412/Social+Work+Research+Report+FINAL_2020.pdf

Department of Internal Affairs. (ឆ្នាំ 2019ខែឧសភា) ‘Digital inclusion stocktake: What digital inclusion looks like across government.’ https://www.digital.govt.nz/dmsdocument/155-digital-inclusion-stocktake-what-digital-inclusion-looks-like-across-government/html#executive-summary

Digital Inclusion Research Group. (ឆ្នាំ2017ខែឧសភា). ‘Digital New Zealanders: The Pulse of our Nation.’ MBIE and DIA. https://www.mbie.govt.nz/dmsdocument/3228-digital-new-zealanders-the-pulse-of-our-nation-pdf

UN General Assembly. (ឆ្នាំ 2016ខែតុលា ថ្ងៃទី3). ‘New York Declaration for Refugees and Migrants: resolution / adopted by the General Assembly.’ Refworld. https://www.refworld.org/docid/57ceb74a4.html

UNHCR. (ឆ្នាំ2018ខែសីហា ថ្ងៃទី31) ‘Refugees’ and ‘Migrants’— Frequently Asked Questions (FAQs).’ Refworld. https://www.refworld.org/docid/56e81c0d4.html




digital.govt.nz